ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ
លេខៈ ២៧/២២ កបប.ខតឃ

**ជម្រាបមក**

**លោកនាយក ក្រុមហ៊ុន ថបស៊ីលវើរ លីមីធីត (សាខាទី1) (វិស័យកាត់ដេរ)**

អាសយដ្ឋាន ឃុំអំពិលតាពក ក្រុងសួងរាំងឪ ខេត្តត្បូងឃ្មុំ

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ។

**យោង** ៖ លិខិតលេខ ២១៤៧៤៨៣៦៤៧ ចុះថ្ងៃទី២០ ខែ មករា ឆ្នាំ២០២២ របស់ក្រុមហ៊ុន ថបស៊ីលវើរ លីមីធីត (សាខាទី1) ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន៧០៧នាក់ (ស្រី ៦៩០នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ៨៥៧នាក់ (ស្រី៨៣៦នាក់) រយៈពេលចំនួន ៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ។

ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់ កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោកនាយក** ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី **លោកនាយក** ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ)មុនថ្ងៃចូលធ្វើការ ។

អាស្រ័យដូចនេះ សូម **លោកនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោកនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃអង្គារ ៨រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ត្បូងឃ្មុំ ថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២២
**ត.ប. រដ្ឋមន្ត្រី**
**ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ុំ-វាសនា**

**ចម្លងជូនៈ**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍)
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលខេត្ត